សេចក្ដីណែនាំរហ័ស



# អ្វីដែលអ្នកចែកចាយត្រូវដឹង។

**ពន្ធផ្នែកភេសជ្ជៈរបស់រដ្ឋ Philadelphia (Philadelphia Beverage Tax) នឹងមកដល់ឆាប់ៗ។**

- ចាប់ផ្ដើមនៅថ្ងៃទី 1 ខែមករា ឆ្នាំ 2017 ទីក្រុងនឹងដាក់ឱ្យបង់ពន្ធ 1.5 សេនក្នុងមួយអោន (29.57 មីលីលីត្រ) ទៅលើការចែកចាយភេសជ្ជៈមានជាតិផ្អែម រួមមានទឹកស៊ីរ៉ូ និងសារធាតុមានបាសច្រើន ដែលប្រើដើម្បីផលិតភេសជ្ជៈមានជាតិផ្អែម។

- ការបង់ប្រាក់ពន្ធនឹងក្លាយជាការទទួលខុសត្រូវរបស់**អ្នកចែកចាយ** ភេសជ្ជៈមានជាតិផ្អែម។ **ឈ្មួញ** ឬអ្នកលក់រាយនឹងត្រូវទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ ប្រសិនបើពួកគេមិនទិញពីអ្នកចែកចាយដែលបានចុះឈ្មោះ។

- អ្នកគឺជា**អ្នកចែកចាយ** ប្រសិនបើអ្នកគឺជាស្ថាប័នជំនួញ ឬអង្គភាពដែលចែកចាយការលក់ដុំទៅ**ឈ្មួញ** ដែលលក់ឱ្យអ្នកប្រើប្រាស់ក្នុងកម្រិតលក់រាយ។

## តើវាមានអត្ថន័យយ៉ាងដូម្ដេចចំពោះខ្ញុំ?

- ក្នុងនាមជា**អ្នកចែកចាយ** អ្នកត្រូវទទួលខុសត្រូវលើការបង់ប្រាក់នៃពន្ធ Philly Bev លើការចែកចាយនូវភេសជ្ជៈមានជាតិផ្អែមដល់ឈ្មួញដែលមានទីតាំងនៅក្នុងរដ្ឋ Philadelphia។

- ការចុះឈ្មោះគឺជាចាំបាច់ណាស់ ហើយនឹងអាចរកបាននៅលើបណ្ដាញ ចាប់ផ្ដើមពីខែវិច្ឆិកា ឆ្នាំ 2016។ នៅពេលចុះឈ្មោះរួច អ្នកនឹងត្រូវបានគេចាត់ទុកជា**អ្នកចែកចាយដែលបានចុះឈ្មោះ** ហើយឈ្មោះរបស់អ្នកនឹងត្រូវបានបញ្ចូលនៅលើបញ្ជីដែល**ឈ្មួញ** អាចប្រើដើម្បីស្វែងរក**អ្នកចែកចាយ** ដែលត្រូវបានចុះឈ្មោះ។

## តើការនេះមានអត្ថន័យយ៉ាងដូម្ដេចចំពោះឈ្មួញរបស់ខ្ញុំ?

- ប្រសិនបើ**ឈ្មួញ** សម្រេចចិត្តទិញពី**អ្នកចែកចាយ** ដែលមិនបានចុះឈ្មោះ ពួកគេត្រូវតែចុះឈ្មោះបង់ពន្ធដោយខ្លួនពួកគេផ្ទាល់ ឬបើមិនដូច្នោះទេត្រូវប្រឈមនឹងការពិន័យជាប្រាក់ និងទោសបញ្ញត្តិផ្សេងៗ។

- ពីព្រោះតែកាតព្វកិច្ចនេះ ស្ថានភាពនៃការចុះឈ្មោះរបស់អ្នកគឺជាទ្រព្យសម្បត្តិមួយ—ជាពិសេសនៅក្នុងដំណាក់កាលបង្ហាញដំបូងនៃពន្ធ Philly Bev នៅពេលដែលអ្នកចែកចាយជាច្រើនអាចនៅតែត្រូវការអនុវត្ត។

CITY OF PHILADELPHIA
DEPARTMENT OF REVENUE

បន្តទៅខាងក្រោយ →

## សេចក្តីណែនាំរហ័ស

### តើខ្ញុំត្រូវធ្វើអ្វីខ្លះ?

- នៅពេលការចុះឈ្មោះចាប់ផ្តើមនៅខែវិច្ឆិកា ឆ្នាំ 2016 អ្នកអាចទៅកាន់ PhillyBevTax.com កន្លែងដែលអ្នកនឹងរកបានតំណដើម្បីចុះឈ្មោះ។ **អ្នកចែកចាយ**ត្រូវបានលើកទឹកចិត្តឱ្យចុះឈ្មោះមិនឱ្យលើសពីថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2016 ទេ ដើម្បីជៀសវាងការបង្អាក់ ឬថ្លៃចំណាយបន្ថែមណាមួយ។ ទោះជាយ៉ាងណាក៏ដោយ ការចុះឈ្មោះឱ្យបានមុនអាចជាទ្រព្យសម្បត្តិមួយនៃជំនួញ។

- នៅលើរាល់វិក្កយបត្រសម្រាប់ឈ្មួញនៅ Philadelphia អ្នកនឹងត្រូវរួមបញ្ចូល៖
    - ចំនួនអោននៃភេសជ្ជៈមានជាតិផ្អែម ដែលបានចែកចាយ (និង សម្រាប់ទឹកស៊ីរ៉ូ និងសារធាតុមានបាសច្រើនផ្សេងទៀត ចំនួននៃផលិតផលដែលបានបញ្ចប់ ដោយផ្អែកលើសេចក្តីណែនាំរបស់អ្នកផលិត)

    -ឬ-

    - ចំនួនទឹកប្រាក់នៃពន្ធ

- ពន្ធ Philly Bev នឹងផុតកំណត់នៅថ្ងៃទី 20នៃខែនីមួយៗសម្រាប់ខែមុនៗ។ ការបង់ប្រាក់លើកដំបូងរបស់អ្នកនឹងផុតកំណត់នៅថ្ងៃទី 20 ខែកុម្ភៈ ឆ្នាំ 2017 សម្រាប់ពេញមួយខែមករា។ ការបំពេញ និងការបង់ប្រាក់នឹងត្រូវធ្វើនៅលើបណ្តាញ។

### តើខ្ញុំគួរប្រាប់ឈ្មួញរបស់ខ្ញុំអ្វីខ្លះ?

- ដើម្បីជួយអ្នកទាក់ទងជាមួយឈ្មួញរបស់អ្នកលើពន្ធថ្មី ឯកសារផ្សេងៗភ្ជាប់មកជាមួយវិក្កយបត្រត្រូវបានរួមបញ្ចូលនៅក្នុងសំណុំឧបករណ៍នេះ ហើយអាចរកឃើញបាននៅក្នុងទម្រង់ដែលអាចបោះពុម្ពបានតាម PhillyBevTax.com ជាមួយនឹងភាសាតាមអ៊ីម៉ែល ដើម្បីរួមបញ្ចូលការចេញវិក្កយបត្រអេឡិចត្រូនិចរបស់អ្នក។ ទាក់ទងជាមួយនឹងឈ្មួញបច្ចុប្បន្នរបស់អ្នកឱ្យបានឆាប់តាមតែអាចធ្វើបាន ដើម្បីឱ្យភាគីទាំងពីរដឹងអំពីការផ្លាស់ប្តូរដែលនឹងមកដល់ឆាប់ៗ និងដឹងអំពីអ្វីដែលត្រូវរំពឹងទុក។

- សូមប្រាកដថា ឈ្មួញរបស់អ្នកដឹងថា ឈ្មួញត្រូវទទួលខុសត្រូវដោយខ្លួនឯងទាក់ទងនឹងពន្ធ និងលើកទឹកចិត្តពួកគេទៅកាន់ PhillyBevTax.com ដើម្បីទទួលបានព័ត៌មានបន្ថែម។

**ចុះឈ្មោះត្រឹម**
**ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2016។**

PHILLY BEV TAX IS HERE

CITY OF PHILADELPHIA
DEPARTMENT OF REVENUE